**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ៤៧៧-សណ១៧អអក

ភ្នំពេញ, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន ខ្មែរ យូធីឡីធី ត្រេឌីង (ខេ យូ ធី) ខមភេនី សម្រាប់ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុករមាសហែក ខេត្តស្វាយរៀង

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅស្រុករមាសហែក ខេត្តស្វាយរៀង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណរួម (ផលិតកម្ម និងចែកចាយ) ឲ្យក្រុមហ៊ុន ខ្មែរ យូធីឡីធី ត្រេឌីង (ខេ យូ ធី) ខមភេនី ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុករមាសហែក ខេត្តស្វាយរៀង ។ ពេលនេះអាជ្ញាធរអគ្គិសនីកម្ពុជាបានអនុញ្ញាតឲ្យក្រុមហ៊ុន ខ្មែរ យូធីឡីធី ត្រេឌីង (ខេ យូ ធី) ខមភេនី ទិញអគ្គិសនីពីអគ្គិសនីកម្ពុជាមកជំនួសឲ្យការផលិតដោយម៉ាស៊ីនផ្ទាល់ខ្លួន ។ ដោយឃើញថា នៅតំបន់ធ្វើសេវាកម្មរបស់ក្រុមហ៊ុន ខ្មែរ យូធីឡីធី ត្រេឌីង (ខេ យូ ធី) ខមភេនី លែងត្រូវការមធ្យោបាយផលិតកម្មទៀតហើយ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន ខ្មែរ យូធីឡីធី ត្រេឌីង (ខេ យូ ធី) ខមភេនី ដោយប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយវិញ តាមខ្លឹមសារដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចនៅ.......................................... ..........................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅស្រុករមាសហែក ខេត្តស្វាយរៀង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យក្រុមហ៊ុន ខ្មែរ យូធីឡីធី ត្រេឌីង (ខេ យូ ធី) ខមភេនី អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** " ។ល។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**

អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី៥
## លើឯកសារអាជ្ញាបណ្ណលេខ ៣១៩ ឯអ ចុះថ្ងៃទី២៤ ខែសីហា
## ឆ្នាំ២០១១ សម្រាប់ក្រុមហ៊ុន ខ្មែរ យូធីឡីធី ត្រេឌីង (ខេ យូ ធី)
## ខមភេនី ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃ
## ស្រុករមាសហែក ខេត្តស្វាយរៀង

## សម្រាប់ការប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម
## មកអាជ្ញាបណ្ណចែកចាយ

**DECISION ON THE FIFTH REVISION**

TO THE LICENSE DOCUMENT No.319 LD DATED AUGUST 24, 2011 OF KHMER UTILITY TRADING (K U T) COMPANY LTD FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF ROMEAS HAEK DISTRICT, SVAY REANG PROVINCE

**FOR CHANGING THE TYPE OF LICENSE**

**FROM CONSOLIDATED LICENSE TO DISTRIBUTION LICENSE**

ថ្ងៃទី... ខែ... ឆ្នាំ២០១៧

..., 2017